នាងអេសធើរ២:១៦-៣:៦

**[១៦]គេក៏នាំអេសធើរចូលទៅថ្វាយស្តេចអ័ហាស៊ូរុស នៅក្នុងព្រះរាជដំណាក់ នៅខែទី១០ គឺជាខែបុស្ស ក្នុងឆ្នាំទី៧នៃរាជ្យទ្រង់**
**[១៧]ស្តេចទ្រង់ក៏ស្រឡាញ់អេសធើរលើសជាងស្ត្រីឯទៀត ហើយនាងទទួលបានព្រះគុណ នឹងសេចក្តីប្រោសប្រាណ នៅចំពោះទ្រង់ លើសជាងពួកស្រីក្រមុំទាំងប៉ុន្មាន ដល់ម៉្លេះបានជាទ្រង់បំពាក់មកុដរាជ្យ តាំងនាងឡើងជាអគ្គមហេសីជំនួសវ៉ាសធី (នាងអេសធើរ២:១៦-១៧)។**

នៅពេលព្រះរាជាបានឃើញនាងអេសធើរផ្ទាល់ព្រះនេត្រ ស្តេចអង្គនេះ មិនចាំបាច់រងចាំរកមហាក្សត្រីណាមួយអង្គទៀតទេ។ ការប្រលងជ្រើសរើសបវរកញ្ញាត្រូវបញ្ចប់ត្រឹមណេះ។ នាងអេសធើរជាទីពេញចិត្តដល់ស្តេចយ៉ាងខ្លាំង ហើយស្តេចក៏តែងតាំងនាងធ្វើជាអគ្គមហេសីចាប់ពីថ្ងៃនោះតទៅ។

យើងគួរសួរថា តើនាងអេសធើរទទួលជ័យជំនះក្នុងការប្រលងជ្រើសរើសបវរកញ្ញានេះបានដោយរបៀបណា? តើហេតុការណ៍ដែលកើតឡើងនេះ ដោយចៃដន្យ ឬក៏ដោយព្រេងសំណាង? ខ្ញុំយល់ថា មិនមែនជាការចៃដន្យ ក៏មិនមែនព្រេងសំណាងអ្វីដែរ។ ព្រះជាម្ចាស់រៀបចំឧបត្ថម្ភរឿងនេះ ដើម្បីអោយនាងអេសធើរទទួលនាទីនៅចំ

កន្លែងដែលនាងត្រូវបម្រើដល់ព្រះជាម្ចាស់។ ឯកិច្ចបម្រើដល់ព្រះជាម្ចាស់ គឺនាងអេសធើរទទួលនាទីនេះ ដើម្បីការពាររាស្ត្ររបស់ទ្រង់។ ប៉ុន្តែ មុននឹងយើងឃើញដំណើររឿងនោះចេញជារូបរាងច្បាស់លាស់ ព្រះជាម្ចាស់ត្រូវបង្ហាញអោយយើងឃើញនូវវប្បធម៌ប្រពៃណីរបស់ជនជាតិដែលមិនស្គាល់ដល់ព្រះអង្គ។ នៅក្នុងប្រពៃណីរបស់គេ ការជប់លៀង ការផឹកស្រវឹង ការធ្វើអំពើបាបស្មោកគ្រោកផ្សេងៗ ជាផ្នែកនៃដំណើរជីវិតប្រចាំថ្ងៃរបស់គេ។ ម្យ៉ាងវិញទៀត នៅក្នុងឈុតដែលព្រះជាម្ចាស់បើកសម្តែងនេះ ព្រះអង្គចង់បញ្ជាក់ប្រាប់យើងថា ទ្រង់មានសមត្ថភាពអាចបំផ្លាស់ហេតុការណ៍ទាំងឡាយរបស់មនុស្សលោក ក៏ដូចជាហេតុការណ៍របស់សាតាំង ដែលចង់បំផ្លាញរាស្ត្ររបស់ទ្រង់ដែរ។ បើលោកអ្នកដែលជាកូនរបស់ព្រះជាម្ចាស់ កំពុងឆ្លងកាត់ស្ថានភាពណាមួយដ៏លំបាក សូមទទួលការលើកទឹកចិត្តពីហេតុការណ៍ ដូចលោកអ្នកបានឃើញមានកើតឡើងខាងលើនេះផងចុះ។ បន្ទាប់ពីស្តេចរកមហេសីបានហើយ នៅក្នុងអត្ថបទខាងលើ សម្តែងថា ស្តេចស្រឡាញ់នាងអេសធើរយ៉ាងជក់ចិត្ត។

ខ្ញុំសូមសារភាពទៅចុះថា ខ្ញុំមិនសូវមានចិត្តរំភើបចំពោះស្នេហារបស់អ្នកទាំងពីរនេះប៉ុន្មានទេ។ នៅក្នុងគម្ពីរនាងរស់ យើងឃើញស្នេហារបស់លោកបូអូស និងនាងរស់ មានភាពល្អកល្អិនយ៉ាងផ្អែមល្ហែម។ ស្នេហារបស់អ្នកទាំងពីរផុសពេញពីដួងចិត្តរបស់គេរៀងខ្លួន។ ស្នេហារវាងលោកបូអូស និងនាងរស់ គឺជានិមិត្តរូបនៃសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទចំពោះក្រុមជំនុំរបស់ទ្រង់។ នៅក្នុងករណីស្នេហារវាងស្តេចអ័ហាស៊ូរុស និងនាងអេសធើរ ស្នេហាប្រភេទនេះមិនផុសចេញពីដួង

ចិត្តរៀងខ្លួនទេ។ ស្តេចអ័ហាស៊ូរុសជាមនុស្សចាស់។ ឯនាងអេសធើរ ជាក្រមុំដែលទើបនឹងពេញវ័យរៀបការ។ បើយើងប្រៀបធៀបដំណើររឿងរបស់នាងអេសធើរ ហើយនិងស្តេចអ័ហាស៊ូរុស យើងឃើញថា អ្នកទាំងពីរមានលក្ខណៈដូចជាពាក្យទំនៀមមួយ ដែលគេប្រៀបធៀបពីសត្វគោ។ កាលគោនៅក្មេង គេហៅគោចាំ ពីព្រោះគេចាំទឹម។ ដល់គោពេញទឹម គេហៅគេចង ពីព្រោះគេចងវាទុកសម្រាប់ទឹម។ លុះគោប្រើការមិនកើត គេហៅគោចាស់ ពីព្រោះគោចាស់រង់ចាំតែគេសម្លាប់ប៉ុណ្ណោះ។ ស្តេចអ័ហាស៊ូរុសជាគោចាស់។ រីឯនាងអេសធើរជាស្មៅខ្ចី។ ឥឡូវគោចាស់ប៉ះស្មៅខ្ចី។ រឿងនេះជារឿងស្តេចមួយអង្គមានរូបរាងដូចគោចាស់ ដើរមកប្រទះនឹងយុវនារីម្នាក់ដែលនៅវ័យក្មេងនៅឡើយ។ ដំណើររឿងស្នេហារបស់នាងអេសធើរ និងស្តេចស៊ូរុស ឥតមានខ្លឹមសារអ្វីអោយដូចព្រះអម្ចាស់យេស៊ូវស្រឡាញ់ដល់ពួកជំនុំទ្រង់ឡើយ។

ប៉ុន្តែ ទោះជាព្រឹត្តិការណ៍នោះ មានលក្ខណៈខុសពីប្រក្រតីក៏ដោយ រឿងនោះមានសារៈសំខាន់ណាស់។ នាងអេសធើរជាកូនរបស់ជនឈ្លើយសឹក ពេលនេះ បានឡើងធ្វើជាអគ្គមហេសីរបស់ស្តេចដែលគ្រប់គ្រងនៅលើ១២៧នរគ។ ដោយសារមុខនាទីរបស់នាង ជនណាដែលស្អប់សាសន៍អ៊ីស្រាអែល ត្រូវពិចារណាម្តងទៀតថា តើគួរស្អប់ ឬគួរប្តូរចិត្តចាប់ពីពេលនេះតទៅ។ ព្រះជាម្ចាស់លើកនាងអេសធើរអោយធ្វើជាកូនសោ សម្រាប់ដោះស្រាយគ្រោះថ្នាក់ដែលសាសន៍យូដាត្រូវជួបប្រទះក្នុងពេលខាងមុខ។

**រួចស្តេចទ្រង់ជប់លៀងជាយ៉ាងធំ ដល់អស់ទាំងពួកអ្នកជាប្រធាន នឹងពួកជំនិតទ្រង់ទាំងអស់ គឺជាការជប់លៀងរបស់អេសធើរ ទ្រង់ក៏ប្រោស ឱ្យមនុស្សនៅគ្រប់ខេត្តបានឈប់សំរាក ហើយទ្រង់ដាក់ទានតាមសណ្ឋានស្តេច (នាងអេសធើរ២:១៨)។**

ដំណើររឿងនាងអេសធើរ ចាប់ផ្តើមដោយពិធីជប់លៀងយ៉ាងធំ។ ឥឡូវយើងឃើញមានពិធីជប់លៀងមួយយ៉ាងធំទៀតហើយ។ ឯពិធីជប់លៀងលើកនេះ គឺជប់លៀងដើម្បីតែងតាំងនាងអេសធើរអោយធ្វើជាអគ្គមហេសី។ ដោយសារស្តេចរកបានអគ្គមហេសីដ៏ល្អមួយរូប ស្តេចប្រកាសមិនយកពន្ធដារពីពលរដ្ឋអស់រយៈពេលមួយឆ្នាំ។ ចំពោះប្រទេសដែលត្រូវបង់ពន្ធធ្ងន់ធ្ងរ ការមិនយកពន្ធដារក្នុងមួយឆ្នាំ ធ្វើអោយពលរដ្ឋមានសេចក្តីរីករាយយ៉ាងខ្លាំង។

**លុះដល់ពួកនាងក្រមុំបានប្រជុំគ្នាលើកទី២ នោះម៉ាដេកាយគាត់អង្គុយនៅត្រង់មាត់ទ្វារព្រះរាជវាំង (នាងអេសធើរ២:១៩)។**

បន្ទាប់ពីនាងអេសធើរឡើងធ្វើអគ្គមហេសី លោកម៉ាដេកាយក៏បានឡើងបុណ្យស័ក្តិដែរ។ លោកមានភារៈអង្គុយនៅទ្វារក្រុង។ សម័យដើម អ្នកដែលត្រូវអង្គុយនៅទ្វារក្រុង គឺជាចៅក្រមមានមុខមានមាត់នៅក្នុងនរគ។ ទ្វារក្រុងជាកន្លែងកាត់ក្តីដល់

អ្នកទោស។ នៅក្នុងព្រះគម្ពីរមានសម្តែងពីដំណើរនោះជាច្រើនលើក ច្រើនសារ។ ឧទាហរណ៍ដូចជា លោកឡុតអង្គុយនៅទីក្រុងសូដុំម ធ្វើជាចៅក្រម កាត់ទោសដល់ពលរដ្ឋនៅក្នុងទីនោះ។ លោកបូអូស ត្រូវនាំរឿងក្តីរបស់នាងរស់ទៅដោះស្រាយទ្វារទីក្រុង។ ឥឡូវនេះ លោកម៉ាដេកាយបានទទួលនាទីធ្វើជាចៅក្រមប្រចាំតុលាការជាន់ខ្ពស់ នៅក្នុងចក្រភពពើស៊ីទាំងមូល ដែលមាននគរ១២៧ជាចំណុះ។

សូមយើងពិនិត្យមើលតួនាទីរបស់លោកម៉ាដេកាយ។ តាំងពីនាងអេសធើរបានឡើងធ្វើជាអគ្គមហេសី លោកម៉ាដេកាយក៏ឡើងបុណ្យស័ក្តិធ្វើជាមេនៃចៅក្រមដែរ។ ដំណើរនេះ គឺជារឿងបក្សពួកនិយមនៅក្នុងជួររាជការ។ ពាក្យថា បក្សពួកនិយម មានន័យថា ជននោះមាន ឬគ្មានសមត្ថភាព អោយតែមានខ្សែជាប់ជាមួយនឹងអ្នកធំ សុទ្ធតែបានទទួលនាទីល្អនៅក្នុងនរគ។ នៅក្នុងករណីលោកម៉ាដេកាយ នាងអេសធើរបានទូលថ្វាយដល់ស្វាមីរបស់នាងថា "លោកម៉ាដេកាយប្រៀបដូចជាឪពុករបស់ខ្ញុំ លោកមានសមត្ថភាពគ្រប់គ្រាន់ ដូច្នេះ សូមព្រះរាជាមេត្តារកនាទីណាមួយជូនលោកផង"។ ស្វាមីរបស់នាងឆ្លើយថា "អើ! យើងក៏ធ្លាប់គិតពីម្នាក់នោះដែរ ឥឡូវ នៅរោងជំនុំជំរះក្តីទ្វារខាងកើត មិនទាន់មាននរណាទទួលខុសត្រូវនៅឡើយទេ សូមដាក់គាត់អោយទទួលនាទីនោះចុះ"។ របៀបដែលលោកម៉ាដេកាយទទួលបុណ្យស័ក្តិ យើងឃើញថា អ្នកនយោបាយមានគំនិតដូចគ្នាតាំងពីមានមនុស្សរស់នៅលើផែនដីនេះមក។ គេតែងតែដាក់បងដាក់ប្អូន ដាក់បក្សដាក់ពួករបស់គេអោយទទួលនាទីល្អៗនៅក្នុងជួររាជការ។

**ឯអេសធើរ នាងមិនបានប្រាប់ឱ្យអ្នកណាដឹង ពីគ្រួ នឹងពីជំនួរវង្សរបស់ខ្លួនទេ តាមបង្គាប់របស់ម៉ាដេកាយ ពីព្រោះនាងនៅតែស្តាប់បង្គាប់ម៉ាដេកាយ ដូចនៅគ្រាដែលគាត់ចិញ្ចឹមនៅឡើយ (នាងអេសធើរ២:២០)។**

ចំណែកនាងអេសធើរវិញ ក៏មានលក្ខណៈវិសេសម្យ៉ាងដែរ។ ទោះបីនាងបានឡើងធ្វើជាអគ្គមហេសី នាងមិនភ្លេចឪពុកចិញ្ចឹមរបស់នាងទេ។ យើងពិបាកនឹងរកមនុស្សដូចនាងអេសធើរណាស់។ មនុស្សខ្លះបានបាយបានទឹកឆ្អាញ់ ភ្លេចក្តាមភ្លេចខ្យង ភ្លេចប្រាច់ ភ្លេចព្រលិតអស់ហើយ។ លោកម៉ាដេកាយជាបុគ្គលម្នាក់ដែលមានលក្ខណៈសំខាន់ណាស់ដែរនៅក្នុងព្រះគម្ពីរ។ មនុស្សច្រើនណាស់មិនសូវយកចិត្តទុកដាក់នឹងលោកទេ។ លោកមានសមត្ថភាពគួរអោយយើងគោរព។

មកទល់ពេលនេះ យើងឈានមកដល់ស្នូលនៃសាច់រឿងក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរទាំងមូលហើយ។ ធម្មតាទ្វារអាចបើកបិទបានដោយសារត្រចៀក។ ព្រះជាម្ចាស់បំពេញតួនាទីរបស់ព្រះអង្គធ្វើជាត្រចៀកទ្វារសម្រាប់រាស្ត្រទ្រង់។ ទ្រង់កំពុងធ្វើសកម្មភាពនៅពីក្រោយស្ថានការណ៍។

**២១ រីឯនៅគ្រានោះ កាលម៉ាដេកាយកំពុងតែអង្គុយនៅមាត់ទ្វារព្រះរាជវាំង នោះមានភ្នាក់ងាររបស់ស្តេច២នាក់ ឈ្មោះប៊ីកថាន**

> **នឹងថេរែស ក្នុងពួកអ្នកចាំយាមនៅមាត់ទ្វារព្រះរាជវាំង គេមាន**
> **សេចក្ដីកំហឹង ហើយរកឱកាសដល់ព្រះជន្មស្ដេចអ័ហាស៊្វេរុស**
> **២២ រឿងនោះក៏បានដឹងដល់ម៉ាដេកាយ ហើយគាត់ទូលអេសធើរជា**
> **អគ្គមហេសី រួចអេសធើរ នាងទូលដល់ស្ដេច ដោយនូវឈ្មោះ**
> **ម៉ាដេកាយ ២៣ លុះកាលគេស៊ើបសួររកពីរឿងនោះទៅ ក៏ឃើញ**
> **ពិតដូច្នោះមែន រួចគេចងកអ្នកទាំង២ព្យួរនៅដើមឈើ ហើយគេ**
> **កត់រឿងនោះទុកក្នុងរបាក្សត្រនៅចំពោះស្ដេច (នាងអេសធើរ**
> **២:២១-២៣)។**

ព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងខខាងលើ បញ្ជាក់ពីព្រះហស្ដរបស់ព្រះជាម្ចាស់កំពុងធ្វើការពីក្រោយស្ថានភាព ដែលមនុស្សលោកជួបប្រទះ។ លោកម៉ាដេកាយអង្គុយនៅទ្វារខាងកើត ពីព្រោះលោកជាចៅក្រម។ ទ្វារទីក្រុងទិសខាងកើតជាទ្វារសំខាន់ជាងគេបង្អស់។ មនុស្សរាប់រយរាប់ពាន់ ចេញចូលតាមទ្វារនោះក្នុងមួយថ្ងៃៗ។ នៅពេលដែលលោកកំពុងតែអង្គុយ លោកបានឮមនុស្សពីរនាក់និយាយពីនាមរបស់ស្ដេច។ លោកក៏រកមធ្យោបាយដើម្បីអែបទៅជិតអ្នកនោះ អោយដឹងថា តើគេនិយាយពីរឿងអ្វី។ លោកបានដឹងថា មានមនុស្សពីរនាក់ ប៉ងធ្វើគុតស្ដេច។ បន្ទាប់ពីឮរឿងនោះហើយ លោកម៉ាដេកាយបានយករឿងនោះ ទៅប្រាប់ដល់នាងអេសធើរជាបន្ទាន់។

រឿងដែលកើតមានឡើងខាងលើ ជារឿងធម្មតា ពិសេសចំពោះស្តេចដែលនៅក្នុងលោកខាងកើត។ សម័យដើម ប្រទេសនានាក្នុងលោកខាងកើត មិនមានសិទ្ធិប្តូរស្តេច ឬអ្នកដឹកនាំរបស់ខ្លួនទេ។ បើគេចង់ប្តូរ មានតែធ្វើរដ្ឋប្រហារ ឬក៏សម្លាប់អ្នកដឹកនាំចោលតែប៉ុណ្ណោះ។ លោកម៉ាដេកាយទទួលមុខនាទីមួយយ៉ាងសំខាន់ បានជាលោកអាចស្តាប់បានរឿងដែលគេចង់ធ្វើគុតស្តេច។

លោកម៉ាដេកាយយករឿងនោះទៅប្រាប់ដល់នាងអេសធើរ នាងអេសធើរយករឿងនោះទៅទូលថ្វាយដល់ស្វាមីរបស់នាង។ នាងអេសធើរប្រហែលទូលស្វាមីនាងថា "ព្រះអង្គជ្រាបហើយថា កាលមុន ទូលបង្គំបាននិយាយពីលោកម៉ាដេកាយ ហើយព្រះអង្គបានលើកលោកអោយធ្វើជាចៅក្រម។ ឥឡូវ លោកកំពុងបំពេញតួនាទីរបស់លោកហើយ ដ្បិតលោកបានដឹងថា មានមនុស្សចង់ធ្វើគុតព្រះអង្គ"។ ស្តេចបង្គាប់ដល់ក្រុមស៊ើបអង្កេត ទៅតាមដានរឿងនោះ ក៏ឃើញថា មានអ្នកចង់ធ្វើគុតព្រះអង្គមែន។ ក្រោយពីបានដឹងហើយ ស្តេចក៏ចេញបញ្ជាចាប់អ្នកទាំងពីរនាក់នោះមក។ អ្នកទាំងពីរក៏សារភាពថា ខ្លួនបានមានគម្រោងយ៉ាងដូច្នោះមែន។ ស្តេចមិនចាំបាច់យកទៅដាក់គុកបង្អស់បាយចំណាយសម្លរអស់ប្រាក់ អ្នកបង់ពន្ធដារទេ។ ស្តេចអង្គនេះសម្លាប់អ្នកទាំងពីរចោលតែម្តង។ ការកាត់ទោសបែបនេះអាចធ្វើអោយជនដទៃទៀត ដែលប៉ងធ្វើគុតស្តេចទទួលការរៀងចាល។ សម័យដើមយើងដឹងថា គេមិនសូវមានអរិយធម៌ ប៉ុន្តែ បើយើងសង្កេតមើលត្រង់ចំណុចនេះ ឧក្រិដ្ឋជនមិនអាចមានអាយុវែង នាំខាតពេលវេលា ខាតបាយ ខាតទឹក ដូចសម័យយើងដែលរាប់ថា មានអរិយធម៌ខ្ពង់ខ្ពស់ទេ។

ហេតុការណ៍ដែលកើតឡើងនេះ ត្រូវគេកត់ទុកនៅក្នុងបញ្ជីពង្សាវតាររបស់ស្តេច។

ម្យ៉ាងទៀត ខ្ញុំចង់អោយលោកអ្នកបងប្អូនពិនិត្យអោយបានល្អិតល្អន់ថា លោកម៉ាដេកាយ មិនបានទទួលគុណបំណាច់ដោយសារបានជួយជីវិតស្តេចទេ។ លោកម៉ាដេកាយសួរខ្លួនឯងថា ខ្ញុំខំបម្រើស្តេច ទាំងប្តូរជីវិតជំនួសផង ហេតុអ្វីក៏មិនបានឡើងបុណ្យស័ក្តិ។ ស្តេចជ្រាបហើយថា លោកម៉ាដេកាយជាអ្នកជួយជីវិតទ្រង់។ ហេតុអ្វីបានជាស្តេចព្រងើយកន្តើយ? ព្រះជាម្ចាស់កំពុងគ្រប់គ្រងស្ថានភាពនេះ។ ការឧបត្ថម្ភគាំទ្រពីព្រះជាម្ចាស់ កំពុងនាំព្រឹត្តការណ៍នេះយ៉ាងប្រកិតពីក្រោយឆាក។

# ជំពូក ៣

***ជាទចនា*** *លោកហាម៉ានបើកយុទ្ធនាការទាស់នឹងសាសន៍យូដា*

នៅក្នុងជំពូក៣ យើងឃើញមានការប៉ុនប៉ងសម្លាប់ផ្ដាច់ពូជសាសន៍យូដាដែលកន្លងមក យើងឃើញគេធ្វើម្ដងហើយម្ដងទៀត តែមិនដែលសម្រេចបំណងរបស់គេ។ បើលោកអ្នកនៅចាំនៅឡើយ នៅក្នុងគម្ពីរនិក្ខមនំ ស្ដេចផារ៉ោនបានចំណាយពេលអស់រយៈ៤០០ឆ្នាំ ដើម្បីសម្លាប់សាសន៍យូដាអោយផុតពូជ។ ស្ដេចផារ៉ោនមិនអាចសម្រេចទិសដៅរបស់លោកបានឡើយ។ នៅក្នុងប្រវត្តិសាស្ត្រពីបុរាណ ហាម៉ាននិងស្ដេចផារ៉ោនមានគំនិតដូចគ្នា។ រីឯនៅក្នុងប្រវត្តិសាស្ត្រសម័យបច្ចុប្បន្ន ពិសេស ក្នុងសង្គ្រាមលោកលើកទីពីរ លោកអ៊ីត្លែ ដែលជាមេដឹកនាំជនជាតិអាល្លឺម៉ង់ បានយកពួកសាសន៍យូដាទៅសម្លាប់ផ្ដាច់ពូជដែរ តែគេធ្វើមិនបានសម្រេច។ សាសន៍អ៊ីស្រាអែលត្រូវគេប៉ុនប៉ងសម្លាប់ផ្ដាច់ពូជជាច្រើនលើក ច្រើនសារណាស់មកហើយនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោក។ ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះអង្គសន្យាថា ទ្រង់នឹងរក្សាសាសន៍អ៊ីស្រាអែលអោយនៅគង់វង្សរហូតពេលបច្ចុប្បន្ន។ គ្មានចលនាណា គ្មានបុគ្គលណាដែលអាចសម្លាប់រាស្ត្ររបស់ព្រះអង្គបានជាដាច់ខាត។

**ក្រោយនោះមក ស្តេចអ័ហាស៊ូរុសទ្រង់លើកដំកើងហាម៉ាន កូនហាំម្តាថា ជាសាសន៍អ័កាក់ ទាំងលើកលោកឡើង តាំងឱ្យមានងារជាធំលើសអស់ទាំងអ្នក ជាប្រធានដែលនៅចំពោះទ្រង់ (នាងអេសធើរ៣:១)។**

ឥឡូវ យើងឃើញមានមនុស្សម្នាក់ទៀតឈ្មោះហាម៉ាន។ លោកហាម៉ានជាបុគ្គលម្នាក់ដែលស្អប់សាសន៍យូដាយ៉ាងខ្លាំង។ ស្តេចបានលើកហាម៉ានអោយមានឋានៈស្មើនឹងនាយករដ្ឋមន្ត្រី។ លោកហាម៉ានជាសាសន៍អ័កាក់។ បើលោកអ្នកអានគម្ពីរ ១សាំយូអែល១៥:៨ សាសន៍អ័កាក់ ត្រូវជារាជវង្សនៅក្នុងត្រកូលអ័ម៉ាលេក។ ពេលនោះស្តេចស៊ូលមិនបានស្តាប់បង្គាប់ដល់ព្រះជាម្ចាស់ទេ គឺទុកអោយសាសន៍អ័កាក់រស់នៅ។ បើស្តេចស៊ូលស្តាប់បង្គាប់ដល់ព្រះជាម្ចាស់នៅក្នុងគ្រានោះ ម្ល៉េះសមនៅក្នុងពេលនេះមិនមានសាសន៍អ័កាក់ប៉ុនប៉ងសម្លាប់សាសន៍យូដាផ្តាច់ពូជទេ។ ព្រះជាម្ចាស់ទតឃើញរាប់ពាន់ឆ្នាំកន្លងមកហើយថា ហេតុការណ៍ដែលកើតមានឡើងនៅក្នុងគម្ពីរនាងអេសធើរ ពិតជាត្រូវមានយ៉ាងដូច្នេះ។ ដូច្នេះហើយ បានជាព្រះអង្គបង្គាប់អោយស្តេចសូលសម្លាប់សាសន៍អ័កាក់ចោលកុំអោយសល់។ ប៉ុន្តែ ទោះបីស្តេចសូលមិនបានសម្លាប់សាសន៍អ័កាក់អោយដាច់ពូជក៏ដោយ ព្រះជាម្ចាស់នៅតែឧបត្ថម្ភ គាំទ្ររាស្ត្ររបស់ទ្រង់ ដោយព្រះអង្គធ្វើការពីក្រោយឆាក។ ទ្រង់ការពាររាស្ត្រទ្រង់ជានិច្ច។

នៅក្នុងលោកនេះ ទោះមានគ្រឿងអាវុធយុទ្ធភ័ណ្ឌទំនើបកម្រិតណាក៏ដោយ ក៏មិនអាចទាស់ជាមួយនឹងសាសន៍អ៊ីស្រាអែលបានទេ។ យើងគិតថា ជនជាតិអាល្លឺម៉ង់ ដែលមានមហិច្ឆតាចង់ធ្វើជាជនផ្តាច់ការ គ្រប់គ្រងសកលលោកទាំងមូលក្រោមអំណាចរបស់លោកអ៊ីត្លែ។ អាចសម្លាប់សាសន៍អ៊ីស្រាអែលផ្តាច់ពូជនៅក្នុងសង្គ្រាមលោកលើកទីពីរ។ ប៉ុន្តែ រឿងនោះ គេមិនអាចសម្រេចបានឡើយ។ សង្គ្រាមទាំងអម្បាលមាណ មានសង្គ្រាមលោកលើកទីមួយ លោកលើកទីពីរ និងសង្គ្រាមវៀតណាម មិនគួរកើតមានឡើយ។ ព្រះជាម្ចាស់អាចបញ្ឈប់ចលនាអាក្រក់ទាំងអម្បាលមាណបាន។ យើងឃើញឧទាហរណ៍នៅក្នុងហេតុការណ៍នាងអេសធើរ គឺព្រះអង្គអាចបញ្ឈប់ហាម៉ាន ពីការប៉ុនប៉ងបំផ្លាញរាស្ត្ររបស់ទ្រង់។ ព្រះអង្គពិតជាមានសមត្ថភាពអាចបញ្ឈប់អំពើអាក្រក់ ទោះបីអាក្រក់មានទំហំប៉ុនសង្គ្រាមក៏ដោយ។ ព្រះអង្គបញ្ឈប់លោកហាម៉ាន មិនអោយធ្វើការអាក្រក់ដល់រាស្ត្រទ្រង់។ ទ្រង់ធ្វើការនោះ ដោយលើកនាងអេសធើរ ធ្វើជាអគ្គមហេសីរបស់ស្តេចចក្រភពពើស៊ី។ បើនាងអេសធើរមិនបានឡើងធ្វើជា អគ្គមហេសីទេ ម្ល៉េះសមសាសន៍យូដាត្រូវគេសម្លាប់ផ្តាច់ពូជអស់ក្នុងពេលនេះហើយ។

**ដូច្នេះ ពួកមហាតលិករបស់ស្តេច ដែលនៅត្រង់មាត់ទ្វារព្រះរាជវាំង គេឱនខ្លួនចុះគោរពដល់ហាម៉ានទាំងអស់គ្នា ពីព្រោះស្តេចទ្រង់បានចេញបង្គាប់ ពីដំណើរលោកយ៉ាងនោះ តែម៉ាដេកាយមិនបានឱនខ្លួនទេ ក៏មិនគោរពផង (នាងអេសធើរ៣:២)។**

ព្រះរាជាបានចេញប្រកាសប្រាប់ដល់ពួកបណ្តាជនថា ព្រះអង្គបានតែងតាំងនាយករដ្ឋមន្ត្រីថ្មីហើយ។ ជនណាក៏ដោយ កាលណាឃើញនាយករដ្ឋមន្ត្រីថ្មី ត្រូវឱនកាយគោរពដល់បុគ្គលនោះ។

ក្នុងពេលនេះដែល លោកម៉ាដេកាយជាចៅក្រមប្រចាំទ្វារក្រុងទិសខាងកើត។ លោកជាសមាជិករបស់រាជការមួយរូប។ ក្នុងនាមលោកជារាជការ លោកត្រូវឱនក្រាបចំពោះលោកហាម៉ាន ជានាយករដ្ឋមន្ត្រី។ ប៉ុន្តែ ព្រះគម្ពីរបានសម្តែងអោយយើងដឹងថា លោកម៉ាដេកាយមិនបានឱនកាយគោរពដល់លោកហាម៉ានទេ។ លោកអ្នកបងប្អូនអើយ នៅក្នុងពេលនេះ ខ្ញុំសូមជម្រាបលោកអ្នកថា ខ្ញុំសុំជូរសម្តី ដូរគំនិតរបស់ខ្ញុំ ពីដំណើរលោកម៉ាដេកាយដែលខ្ញុំធ្លាប់បាននិយាយមិនល្អពីគាត់ កាលពីលើកមុន។ ខ្ញុំសម្តែងការគោរពដល់លោកម៉ាដេកាយយ៉ាងខ្លាំង ពីព្រោះលោកបានសម្តែងខ្លួនលោកថាជាអ្នកថ្វាយបង្គំដល់ព្រះជាម្ចាស់។ លោកមិនព្រមឱនកាយគោរពដល់លោកហាម៉ាន។

ចាប់ពីពេលនេះទៅ យើងឃើញថា ព្រះហស្តរបស់ព្រះជាម្ចាស់ កំពុងធ្វើការក្នុងជីវិតរបស់លោកម៉ាដេកាយហើយ។ ឆាកឈុតដែលយើងកំពុងឃើញនេះ សបញ្ជាក់ថា ព្រះជាម្ចាស់បានធ្វើអោយរូបភាពនៃកិច្ចការទ្រង់ លេចពេញមកកាន់តែច្បាស់បន្តិចម្តង១។ យើងសួរថា បើលោកម៉ាដេកាយរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ តើធ្វើដូម្តេច អោយព្រះអង្គធ្វើការជាមួយនឹងមនុស្សបែបនោះកើត? មែនហើយ គាត់គួរតែត្រឡប់ទៅប្រទេសអ៊ីស្រាអែលវិញ។ ប៉ុន្តែ ទោះបីលោកមិនបានត្រឡប់ទៅនគររបស់លោកក៏ដោយ លោកប្រាប់គេថា លោកជាសាសន៍យូដា។ លោក

រស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ តែលោកទទួលស្គាល់យ៉ាងឧឡារិក ព្រះជាម្ចាស់គឺជាព្រះតែមួយអង្គគត់ដែលលោកគោរពនិងថ្វាយបង្គំ។ លោកហាមប្រាម ដល់នាងអេសធើរមិនអោយនិយាយប្រាប់គេថា នាងជានរណាទេ តែលោកទទួល ស្គាល់ថា ព្រះជាម្ចាស់គឺជាព្រះរបស់សាសន៍អ៊ីស្រាអែល។ ហេតុអ្វីបានជាខ្ញុំអោយតម្លៃ ដល់កិរិយាប្រព្រឹត្តរបស់លោកម៉ាដេកាយ ដោយមិនបានក្រាបគោរពចំពោះលោក ហាម៉ាន? ក្នុងនាមលោកម៉ាដេកាយជាសាសន៍យូដា លោកចាំបាច់ត្រូវធ្វើតាមព្រះ បន្ទូលរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ហាមប្រាមមិនអោយរាស្ត្ររបស់ទ្រង់ក្រាបថ្វាយ បង្គំអ្នកណាឡើយ គឺត្រូវថ្វាយបង្គំតែព្រះមួយអង្គប៉ុណ្ណោះ។ សាសន៍យូដាមិនត្រូវ ឆ្លាក់ធ្វើរូបសំណាកណាមួយ ដើម្បីថ្វាយបង្គំដែរ។ លោកហាម៉ានដែលមាននាទីជា នាយករដ្ឋមន្ត្រី តាំងខ្លួនលោកធ្វើដូចជាព្រះមួយអង្គណាមួយយ៉ាងដូច្នោះ។ អ្នកណា ក៏ដោយ សុទ្ធតែលូនក្រាបនៅចំពោះហាម៉ាន ដើម្បីសុំបុណ្យស័ក្តិ។ ដោយឡែកតែ លោកម៉ាដេកាយ លោកមិនបានក្រាបថ្វាយបង្គំដល់លោកហាម៉ានទេ។ នៅក្នុងសង្គម មួយដែលមនុស្សទាំងអស់ត្រូវឱនក្រាប ដើម្បីរស់នៅ កាលណាលោកម៉ាដេកាយឈរ ម្នាក់ឯង គេច្បាស់ជាយល់ថា ជាមនុស្សឆ្កួតជាមិនខាន។

លោកម៉ាដេកាយនិងនាងអេសធើរ មិនបានត្រឡប់ទៅនគររបស់ខ្លួនវិញ តែ អ្នកទាំងពីរព្រមប្រឈមមុខនឹងគ្រោះថ្នាក់ ដោយប្តូរជីវិតជំនួសរាស្ត្ររបស់ខ្លួន។ ដូច្នេះ អ្វីៗដែលខ្ញុំនិយាយអាក្រក់ពីលោកម៉ាដេកាយពីមុន ខ្ញុំសូមកែត្រឹមពីពេលនេះតទៅ។

**[៣]ដូច្នេះ ពួកមហាតលិករបស់ស្តេច ដែលនៅត្រង់មាត់ទ្វារព្រះរាជ
វាំង គេសួរគាត់ថា ហេតុអ្វីបានជាអ្នកទទឹងនឹងបង្គាប់ស្តេចដូច្នេះ
[៤]រួចកាលគេបានរំឭកដល់គាត់រាល់តែថ្ងៃ តែគាត់មិនព្រមស្តាប់
តាមនោះគេក៏ជំរាបដល់ហាម៉ាន ដើម្បីនឹងលមើលបើសេចក្តី
ដែលម៉ាដេកាយប្រព្រឹត្តដូច្នោះ នឹងបាន ឬមិនបាន ពីព្រោះគាត់
បានប្រាប់ឱ្យគេដឹងហើយ ថាគាត់ជាសាសន៍យូដា (នាងអេសធើរ
៣:៣-៤)។**

មានគេសួរដល់លោកម៉ាដេកាយថា ហេតុអ្វីបានជាលោកមិនព្រមក្រាបថ្វាយបង្គំលោកហាម៉ាន។ នៅពេលនេះជាលើកដំបូងបង្អស់ហើយ ដែលលោកម៉ាដេកាយសារភាពប្រាប់អ្នកឯទៀតថា លោកជាសាសន៍យូដា។ ចាប់តាំងពីពេលមុនមកទល់គ្រានេះ លោកមិនដែលប្រាប់នរណាថា លោកជាសាសន៍យូដាជាដាច់ខាត។ មិនតែប៉ុណ្ណោះលោកហាមប្រាមដល់នាងអេសធើរ មិនអោយប្រាប់ដល់អ្នកណាថា នាងជាសាសន៍អ្វីដែរ។ សូម្បីស្វាមីរបស់នាងក៏មិនដឹងថា នាងជាសាសន៍យូដា។ ប៉ុន្តែ ក្នុងវេលានេះ លោកម៉ាដេកាយប្រាប់គេថា មូលហេតុដែលលោកមិនក្រាបថ្វាយបង្គំដល់ហាម៉ានពីព្រោះលោកជាសាសន៍យូដា។ ក្នុងវិនាទីដែលលោកប្រកាសខ្លួនថា លោកជាសាសន៍យូដា លោកប្រកាសខ្លួនរួចជាស្រេចថា លោកមានសាសនាមួយ ឯសាសនារបស់លោកគឺថ្វាយបង្គំដល់ព្រះដ៏ពិត និងព្រះដ៏រស់។ លោកមិនក្រាបថ្វាយបង្គំដល់រូបព្រះរូប

សំណាក ឬបុគ្គលណាឡើយ។ ក្នុងព្រះគម្ពីរចោទិយកថា៦:៤ ព្រះជាម្ចាស់មានបន្ទូលទៅកាន់សាសន៍អ៊ីស្រាអែលយ៉ាងច្បាស់ថា "ចូរស្ដាប់ចុះ ឱអ៊ីស្រាអែលអើយ ព្រះយេហូវ៉ាជាព្រះនៃយើង គឺព្រះយេហូវ៉ាតែ១អង្គទ្រង់"។ លោកម៉ាដេកាយ ធ្វើជាទីបន្ទាល់ដល់មនុស្សដែលរស់នៅក្នុងពិភពលោកសម័យដើមថា នៅក្នុងលោកនេះ មានព្រះមួយអង្គ ដែលគង់នៅក្នុងសំណុំតួអង្គព្រះត្រៃឯក គឺព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ លោកម៉ាដេកាយប្រកាន់ជំហរបែបនេះ បានជាលោកត្រូវគេមើលងាយមើលថោក។ នៅក្នុងពិភពលោកទាំងមូលនរណាក៏ដឹងដែរថា សាសន៍យូដាថ្វាយបង្គំដល់ព្រះមួយគត់ គឺជាព្រះដ៏ពិត និងព្រះដ៏រស់។

ខ្ញុំសូមចូលរួមជាមួយនឹងសេចក្ដីក្លាហានរបស់លោកម៉ាដេកាយ ដែលបានធ្វើពលិកម្ម ដើម្បីព្រះជាម្ចាស់។ ខ្ញុំសូមអភ័យទោស ដែលខ្ញុំនិយាយអាក្រក់ពីលោកកាលពីពេលមុន។ ឥឡូវនេះ លោកម៉ាដេកាយចាប់ផ្ដើមប្រកាន់ជំហររបស់លោកជាមួយព្រះជាម្ចាស់ហើយ។ ការប្រកាន់ជំហរបែបនេះ ច្បាស់ជាលោកត្រូវខាតបង់អ្វីៗខ្លះនៅក្នុងជីវិតរបស់លោកជាមិនខាន។ ខ្ញុំជឿថា លោកម៉ាដេកាយមិនបានជាគិតថា ការប្រកាន់ជំហររបស់លោក អាចមានលទ្ធផលល្អចំពោះសាសន៍លោកយ៉ាងដូចម្ដេចទេ។ ប៉ុន្តែខ្ញុំដឹងច្បាស់ថា លោកហ៊ានបរិច្ចាគ ទោះបីមុខនាទី ទោះបីកេរ្តិ៍ឈ្មោះរបស់លោក។ លោកចង់បញ្ជាក់ប្រាប់គេថា លោកថ្វាយបង្គំដល់ព្រះជាម្ចាស់ជាព្រះដ៏រស់ និងព្រះដ៏ពិតតែមួយអង្គប៉ុណ្ណោះ។

**[៥]កាលហាម៉ានឃើញថា ម៉ាដេកាយមិនឱនគោរពដល់ខ្លួនទេ**
**នោះលោកមានចិត្តពេញដោយសេចក្ដីក្រោធ**
**[៦]តែលោកគោះ**
**គើយ នឹងចង់ចាប់ម៉ាដេកាយតែ១ប៉ុណ្ណោះ ដ្បិតគេបានជំរាបឱ្យ**
**លោកជ្រាបពីសាសន៍របស់ម៉ាដេកាយហើយ បានជាលោករក**
**ឱកាសនឹងបំផ្លាញសាសន៍យូដាទាំងអស់បង់ ដែលមាននៅពេញ**
**ក្នុងនគររបស់អ័ហាស៊ូរុសទាំងមូលវិញ គឺជាជាតិរបស់ម៉ាដេកាយ**
**ទាំងប៉ុន្មាន (នាងអេសធើរ៣:៥-៦)។**

សេចក្ដីពិតខាងលើសម្ដែងថា លោកហាម៉ានជាមនុស្សឆោត។ លោកហាម៉ានមិនគួរយកចិត្តទុកដាក់ជាមួយនឹងកិរិយាប្រព្រឹត្តរបស់លោកម៉ាដេកាយទេ។ កិរិយាប្រព្រឹត្តរបស់លោកម៉ាដេកាយ មិនគំរាមកំហែងអ្វីដល់តួនាទីរបស់លោកឡើយ។ បើលោកគ្រាន់តែគោរពសិទ្ធិសេរីភាពនៃជំនឿរបស់លោកម៉ាដេកាយ នោះចប់រឿងទៅហើយ។ ប៉ុន្តែ លោកហាម៉ានជាមនុស្សឆោតណាស់ សូម្បីរឿងបន្តិចបន្តួចដូចសំរាមក៏លោកយកមកគិតដែរ។ តើនាយករដ្ឋមន្ត្រីដែលគ្រប់គ្រងនគរ១២៧ គួរមានគំនិតស្មៀបរមាស់ដោយសារតែរឿងបន្តិចបន្តួចនេះដែរឬ? លោកហាម៉ានពិតជាមនុស្សឆោតមែន។

លោកហាម៉ានចង់ធ្វើការមួយដ៏អាក្រក់ជាទីបំផុត។ លោកមិនបានដឹងថា នៅក្នុងព្រះគម្ពីរ ព្រះជាម្ចាស់សន្យាដល់លោកអ័ប្រាហាំថា អ្នកណាដែលឱ្យពរដល់លោក

នោះនឹងបានពរ អ្នកណាដែលដាក់បណ្តាសាដល់លោក នោះនឹងទទួលបានបណ្តាសាវិញ។ ព្រះជាម្ចាស់រក្សាពាក្យសន្យារបស់ទ្រង់ណាស់។ នៅក្នុងប្រវត្តិសាស្ត្រ មានមនុស្សជាច្រើន ប៉ងសម្លាប់សាសន៍យូដាអោយដាច់ពូជ តែមិនអាចសម្លាប់បានទេ។ អ្នកដែលស្លាប់ដាច់ពូជ គឺជាអ្នកដែលប៉ងសម្លាប់រាស្ត្រព្រះអង្គ។ ហាម៉ានសម្តែងខ្លួនថា លោកជាមនុស្សរបស់សាតាំង។ លោកចង់សម្លាប់រាស្ត្ររបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់រក្សារាស្ត្ររបស់ទ្រង់ មិនអោយអ្នកណាសម្លាប់បានឡើយ។ យើងឃើញដំណើររឿងដែលព្រះជាម្ចាស់រក្សារាស្ត្ររបស់ទ្រង់ នៅក្នុងព្រះគម្ពីរនាងអេសធើរដែលយើងកំពុងតែសិក្សានេះ។

យើងស្លេះការសិក្សាព្រះគម្ពីរនាងអេសធើរត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ “ដើរជាមួយនឹងព្រះ ពិតជាប្រទះជាមួយនឹងព្រះយេស៊ូវជាមិនខាន!”